**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០២១

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jul-2021, 12:37
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើសុំធ្វើការឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងសំណើរបស់ មាស មុត សុំឲ្យបញ្ចប់ ចោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ**

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គបុរេជំនុំជម្រះ** ៖

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣**

សំណើរបស់ មាស មុតសុំធ្វើការឆ្លើយតបទៅនឹងចម្លើយរបស់ ស.ព.អ. តបទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណាសារ

លោក មាស មុត តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្តី") អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក. ("សេចក្តីណែនាំអនុវត្ត") និង អំណាចដែលជាប់ជាមួយរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ.") ស្នើសុំពិចារណាសំណើសុំធ្វើការឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") តបទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារនេះ[1] ដើម្បីកែតម្រូវការបកស្រាយមិនត្រឹមត្រូវ ខុសពីការពិត និង មិនសមទំនងរបស់ ស.ព.អ. ចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តី។ សំណើនេះ គឺដើម្បីប្រតិបត្តិតាមការបំពេញកិច្ចដោយការយកចិត្តដាក់របស់សហមេធាវីការពារក្តី[2] ដើម្បីជាប្រយោជន៍ដល់សេដ្ឋកិច្ចតុលាការ មិនបណ្តាលឱ្យមានការពន្យារពេលមិនសមស្របចំពោះដំណើរការនីតិវិធីទេ និង ត្រូវបានដាក់ជូនទាន់ពេលវេលា នៅក្នុងរយៈពេលប្រាំថ្ងៃនៃការជូនដំណឹងអំពីចម្លើយរបស់ ស.ព.អ. ជាភាសាអង់គ្លេសផងដែរ[3]។ មេធាវីការពារក្តីស្នើសុំដាក់ជូនការឆ្លើយតបនេះជាភាសាអង់គ្លេសជាមុនសិន ហើយការបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ដោយសារអង្គភាពបកប្រែភាសាមិនអាចបញ្ចប់ការបកប្រែតាមស្តង់ដាកំណត់រយៈពេលប្រាំថ្ងៃចំពោះការឆ្លើយតបបានទេ[4]។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២១ ឯកសារ D272/1 ("ចម្លើយរបស់ ស.ព.អ.")។

[2] ការបំពេញកិច្ចដោយការយកចិត្តទុកដាក់ តម្រូវឱ្យសហមេធាវីរបស់ជនត្រូវចោទ ធ្វើអ្វីមួយ និង គ្រប់យ៉ាង ដើម្បីធានាបានថាគ្រប់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានផ្តល់ដោយពេលលេញដល់កូនក្តីរបស់ខ្លួន រួមទាំងធ្វើការតវ៉ាចាំបាច់ផ្នែកអង្គហេតុ និង អង្គច្បាប់ទាំងអស់ ដោយពិនិត្យមើលលើសច្ចភាព និង ភាពត្រឹមត្រូវនៃភស្តុតាង ដែលសហចៅក្រមស៊ើបអង្កេតបានប្រមូល ហើយដែលត្រូវបានប្រើប្រាស់ប្រឆាំងជនត្រូវចោទនានា។ វិធាន ១.៣ នៃវិធានក្រមវិជ្ជាជីវៈអាឡាស្កា (ALASKA RULES OF PROF'L CONDUCT) (ឆ្នាំ ២០១៧-២០១៨) ។ *ដូចខាងលើ* មតិយោបល់ចំពោះវិធាន ១.៣។ *សូមមើលផងដែរ* មាត្រា ៧ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈគណៈមេធាវី (ឆ្នាំ ១៩៩៥)។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

[3] ចម្លើយរបស់ ស.ព.អ. ត្រូវបានជូនដំណឹងដល់មេធាវីការពារក្តី នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២១។ *សូមមើល* ការជូនដំណឹងរបស់មន្ត្រីគ្រប់គ្រងសំណុំរឿង [ដែលដាក់ដោយ ស.ព.អ.] ឯកសារថ្មី៖ សំណុំរឿង ០០៣ – ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០២១។

[4] សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសា "កម្មវត្ថុ៖ សំណើសុំឱ្យបកប្រែភាសា" ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០២១។ ទោះបីជាចម្លើយរបស់ ស.ព.អ. បានជូនដំណឹងតែជាភាសាអង់គ្លេស មេធាវីការពារក្តីបានដាក់សំណើនេះតាមស្តង់ដាកំណត់រយៈពេលប្រាំថ្ងៃ តាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត ដើម្បីចៀសវាងព្យារពេលណាដល់ការពិចារណាសម្រេចរបស់ អ.ប.ជ.។

## I. សំណើសុំធ្វើការឆ្លើយតប

១. ទោះបីជាការអានសារណាសុំពិចារណារបស់ភាគីមានខុសឆ្គងដោយអចេតនាក្តី ក៏ការធ្វេសប្រហែសនៅក្នុងការថ្លែងអំពីជំហររបស់ភាគី ឬ ការខកខានពុំបានផ្តល់បរិបទសម្រាប់ការអះអាងអាចស្មើនឹងការថ្លែងខុសឆ្គង ឬ ការកំណត់ចារីតលក្ខណៈមិនត្រឹមត្រូវ ដែលតម្រូវឱ្យមានការឆ្លើយតប មួយ។ នេះជាស្ថានភាពបែបនេះ។ ជាក់ស្តែង ចម្លើយ មានលក្ខណៈបំភ័ន្តយ៉ាងចម្លែកមែនទែន និងពោរពេញទៅដោយការបកស្រាយខុសឆ្គងធ្ងន់ធ្ងរ គឺគួរឱ្យសោកស្តាយ ដែលវាត្រូវតែបានចាត់ទុកថាជាសម្តីកុហក - ដែលវាទំនងជាថា ស.ព.អ. ដែលប្រកាន់គោលការណ៍សុជីវធម៌ផ្សេងមុនភ្ជាប់ហត្ថលេខារបស់គាត់ទៅនឹងអ្វីដែលបុគ្គលិករបស់គាត់បានអនុញ្ញាត មិនបានពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ និង ពិចារណាឱ្យសមរម្យទៅលើសច្ចភាពត្រឹមត្រូវនៃអ្វីដែលអះអាងយ៉ាងច្រើន និង ពាក្យពេចន៍បញ្ចិតបញ្ចៀងផ្ទាល់ខ្លួនសំដៅមកលើមេធាវីការពារក្តីនោះទេ។ ស្ទើរគ្រប់កថាខណ្ឌ សុទ្ធតែបង្ហាញពីការកំណត់ចារិតលក្ខណៈមិនត្រឹមត្រូវដោយចេតនានៃជំហរ សេចក្តីថ្លែងការណ៍ដែលនាំឱ្យយល់ខុស និង ការផ្តល់ព័ត៌មានមិនពិតរបស់មេធាវីការពារក្តី ដែលធ្វើឱ្យមានការចាប់អារម្មណ៍ថា មេធាវីការពារក្តីមានចេតនាបកស្រាយមិនត្រឹមត្រូវ ទៅលើអង្គច្បាប់ អង្គហេតុ និង ប្រវត្តិនីតិវិធីនៃរឿងក្តី ០០៣។ ដើម្បីកែតម្រង់ការប្រទុស្តរាយនេះ ទៅលើសុចរិតភាពរបស់មេធាវីការពារក្តី ប៉ុន្តែ សំខាន់ជាងនេះ ដើម្បីបញ្ជាក់បំភ្លឺ និង កែតម្រូវការយល់ខុសដែលនៅតែមានចំពោះអ្វីដែលមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ ការឆ្លើយតបមួយ ដែលមេធាវីការពារក្តីមានសិទ្ធិតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត គឺត្រូវបានធ្វើឡើងជាចំបាច់ និង សមហេតុផល។ លើសពីការប្រុងប្រយ័ត្នបំផុត និង គោរពតាមសេចក្តីណែនាំជាសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះថា មិនតម្រូវឱ្យមានការឆ្លើយតបទេ នោះគួរត្រូវស្នើសំណើសុំធ្វើការឆ្លើយតប[5]។

២. អ.ប.ជ. អាចសម្រេចលើបញ្ហាទាំងឡាយនៅចំពោះមុខខ្លួន តាមរយៈសារណាសុំការពិចារណាជាលាយលក្ខណ៍អក្សរបាន *ប្រសិនបើ*ការឆ្លើយតបមួយត្រូវបានអនុញ្ញាត ជំនួសឱ្យសវនាការផ្ទាល់មាត់ ស្របតាមវិធាន ៨.៤ នៃសេចក្តីណែនាំអនុវត្ត[6]។ ដោយសារ អ.ប.ជ. បានយល់ឃើញថា

---

[5] សេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះជូនដល់ភាគីនានាក្នុងសំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៧) ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១។

[6] មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តចែងថា៖ "ការឆ្លើយតបទៅនឹងសារណាតប ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលផ្ទាល់មាត់ប៉ុណ្ណោះ ហើយការឆ្លើយតបនោះ ត្រូវដាក់ក្នុងរយៈពេល ៥ ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃសារណាតបនោះ ដែលត្រូវឆ្លើយតប"។

សវនាការជាសាធារណៈ លើបណ្ដឹងឧទ្ធរណ៍ខ្វែងប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងរឿងក្ដី ០០៤ មិនត្រូវបានអនុញ្ញាតទេ[7] ទោះបីជាត្រូវបានផ្ដល់ជូនភាគីនៅក្នុងរឿងក្ដី ០០៤/១, ០០៤/២ និង ០០៣[8] រួចមកហើយក្ដី វាមានហេតុផលអាចឱ្យសន្មតបានថា អ.ប.ជ. នឹងមិនប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបើកសវនាលើសំណើសុំខ្វែង បន្ទាប់ពីមានសេចក្ដីពិចារណារបស់ខ្លួនឡើយ។

៣. អ.ប.ជ. ក៏មានសិទ្ធិអំណាចដែលជាប់ជាមួយ ក្នុងការអនុញ្ញាតសំណើសុំធ្វើការឆ្លើយតប "ដើម្បីទទួលព័ត៌មានឱ្យបានពេញលេញអំពីបញ្ហានេះ"[9]ដែរ។ អ.ប.ជ. *អាច* និង *គួរតែ*ពិចារណាទៅលើសេចក្ដីណែនាំជាសារអេឡិចត្រូនិករបស់ខ្លួនថា ពុំតម្រូវឱ្យមានការឆ្លើយតបណាមួយឡើយ ដូចដែលខ្លួនបានអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេលចម្លើយតបទៅនឹងសំណើរបស់ ស.ព.អ. សុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣[10]។ ដោយពិចារណាថា ការកំណត់ចារឹកលក្ខណៈមិនត្រឹមត្រូវ និង ការបកស្រាយខុសឆ្គង

---

[7] *រឿងក្ដី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ ៦១) សេចក្ដីសម្រេចលើសវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០២១ ឯកសារ D381/41 & D382/40។

[8] *រឿងក្ដី អ៊ុំ ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ ៥០) ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D308/3/1/19។ *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ ៦០) ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D360/14 & D395/5។ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៩ ឯកសារ D266/12។

[9] អ.ប.ជ. បានប្រើប្រាស់អំណាចដែលជាប់ជាមួយរបស់ខ្លួន ដើម្បីអនុញ្ញាតតាមការស្នើសុំធ្វើការឆ្លើយតប ទោះបីជាឯកសារដែលមានលក្ខណៈជា "ការឆ្លើយតប" ពី ស.ព.អ. ក្ដី ក្នុងការ"ទទួលព័ត៌មានឲ្យបានពេញលេញអំពីបញ្ហានោះ"។ *សូមមើល* សេចក្ដីសម្រេចជាសាធារណៈដែលបានកោសលុប [ត្រូវបានកោសលុប] អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការខកខានរបស់អង្គភាពគាំពារការការពារក្ដីមិនបានដាក់បញ្ចូលសំណើរបស់គាត់ ដែលត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីគាំពារមេធាវីបរទេស ចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០១៦ ឯកសារលេខ ៤ ជើងទំព័រ ១៧។

[10] សំណើរបស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួន តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/2។ សេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះទៅភាគីទាំងអស់ក្នុងសំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៧) ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០២១។

របស់ ស.ព.អ. នៅបន្តយ៉ាងមានប្រសិទ្ធភាពដល់ទឡ្ហីករណ៍ថ្មី នោះការឆ្លើយតបមួយត្រូវតែមានដើម្បីធ្វើយុត្តិកម្មដល់ការអនុវត្ត និង សមធម៌[11]។

៤. ការមិនអនុញ្ញាតឱ្យមានការឆ្លើយតបមួយ ដើម្បីកែតម្រូវការបកស្រាយខុសឆ្គងយ៉ាងច្បាស់ក្រឡែតរបស់ ស.ព.អ. នាំឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី[12]។ វាបង្កហានិភ័យទុកមានឱ្យការចាប់អារម្មណ៍ដោយភាន់ច្រឡំថា មេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទក្នុងការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសុខចិត្តបញ្ជូនរឿងក្ដីទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ម្នាក់បញ្ជូនរឿងទៅជំនុំជម្រះ រីឯ ស.ច.ស. ម្នាក់ទៀតលើកលែងចោទប្រកាន់ ហើយស្វែងរកការរំលត់រឿងក្ដី ០០៣ *តែប៉ុណ្ណោះ* ប្រសិនបើ អ.ប.ជ. មិនអាចចាប់បានសំឡេងភាគច្រើនលើសលុប ក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ[13]។

អាស្រ័យហេតុនេះ រាល់សំអាងហេតុផលដែលថ្លែងខាងលើនេះ និង ដើម្បីជាប្រយោជន៍យុត្តិធម៌ អ.ប.ជ. គួរតែ **អនុញ្ញាត** តាមសំណើសុំធ្វើការឆ្លើយតបរបស់មេធាវីការពារក្ដី។

សូមលោកចៅក្រមទទួលយកសេចក្ដីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៤** ខែ**កក្កដា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្ដីលោក មាស មុត**

| | |
|---|---|
| អាង ឧត្ដម | Michael G. KARNAVA |

[11] *សូមមើល រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង Kupreškić* សំណុំរឿងលេខ IT-95-16-A សាលដីកាលើបណ្ដឹងសារទុក្ខរបស់ភាគីបណ្ដឹងសារទុក្ខ Vlatko Kupreškić, Drago Josipović, Zoran Kupreškić និង Mirjan Kupreškić ឱ្យទទួលយកភ័ស្ដុតាងបន្ថែម ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៧០។

[12] *ដូចខាងលើ*។

[13] ចម្លើយរបស់ ស.ព.អ. កថាខណ្ឌ ២។